ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

និយ័តករទូរគមនាគមន៍កម្ពុជា

លេខ :...១៦១៥.....ន.ទ.ក.

# សេចក្តីជូនដំណឹង

និយ័តករទូរគមនាគមន៍កម្ពុជា (ន.ទ.ក) មានកិត្តិយសសូមជម្រាបជូន ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោកឧកញ៉ា លោក លោកស្រីជាប្រតិបត្តិករ និងអ្នកទទួលប្រើប្រាស់សេវាទូរគមនាគមន៍ទាំងអស់ ជ្រាបថា៖ ដើម្បីឲ្យមានភាពងាយស្រួល និងឆាប់រហ័ស សន្សំសំចៃពេលវេលាជូនប្រតិបត្តិករ និងអ្នកទទួលប្រើប្រាស់សេវាទូរគមនាគមន៍ទាំងអស់ និយ័តករទូរគមនាគមន៍កម្ពុជា (ន.ទ.ក) បានពិនិត្យ និងកែសម្រួលនីតិវិធីនៃការទូទាត់វិក្កយបត្រ និងកម្រៃផ្សេងៗ មកនិយ័តករទូរគមនាគមន៍កម្ពុជា។ ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោកឧកញ៉ា លោក លោកស្រី អាចធ្វើការទូទាត់តាមនីតិវិធីដូចខាងក្រោម៖

១/ អាចធ្វើការទូទាត់ជាសាច់ប្រាក់ ឬមូលប្បទានប័ត្រនៅបេឡាធិការនៃ ន.ទ.ក ដែលមានអាសយដ្ឋាន វិថីលេខ ១០២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ឬ

២/ អាចធ្វើការទូទាត់តាមការដាក់ប្រាក់ ឬបង្វែរចូលគណនីរបស់និយ័តករទូរគមនាគមន៍កម្ពុជានៅធនាគារពាណិជ្ជកម្មក្រៅប្រទេស (FTB)សម្រាប់ប្រាក់ដុល្លារអាមេរិកគណនីលេខUSD:A/C 010300640009212 និងសម្រាប់ប្រាក់រៀលគណនីលេខ KHR : A/C 010012900000139 ដែលមានគណនីឈ្មោះ និយ័តករទូរគមនាគមន៍កម្ពុជា (ន.ទ.ក) ឬ Telecommunication Regulator of Cambodia (TRC) ឬ

៣/ អាចធ្វើការទូទាត់តាមប្រព័ន្ធInternet Banking របស់ធនាគារពាណិជ្ជកម្មក្រៅប្រទេស(FTB) ដែលមានគេហទំព័រ www.ftbbank.com (ករណីនេះអតិថិជនត្រូវមានគណនីជាមួយធនាគារពាណិជ្ជកម្មក្រៅប្រទេស(FTB) និងចុះឈ្មោះក្នុងប្រព័ន្ធ Internet Banking ឬ

៤/ អាចធ្វើការទូទាត់តាមរយៈ គ្រប់សាខាធនាគារពាណិជ្ជកម្មក្រៅប្រទេស (FTB) ទាំងអស់ក្នុងព្រះរាជាណាចក្រកម្ពុជា ដោយយកភ្ជាប់ជាមួយនូវវិក្កយបត្រ ឬឯកសារពាក់ព័ន្ធដែលត្រូវធ្វើការទូទាត់ រួចជូនដំណឹងមក ន.ទ.ក. តាមរយៈទូរស័ព្ទលេខ ០២៣ ៧២២ ៣៣៣ ។

៥/ រាល់ការកក់ប្រាក់ធានាការចាប់ផ្តើមប្រតិបត្តិការ (Operation Deposit) ប្រតិបត្តិករទាំងអស់សូមធ្វើការដាក់ប្រាក់ ឬបង្វែរចូលគណនីរបស់ ន.ទ.ក នៅធនាគារអេស៊ីលីដាភីអិលស៊ី (ACLEDA) ប្រាក់ដុល្លារអាមេរិក គណនីលេខ US :A/C 00010124926313 និងគណនីឈ្មោះ និយ័តករទូរគមនាគមន៍កម្ពុជា (ន.ទ.ក) ឬ Telecommunication Regulator of Cambodia (TRC) ។

<u>បញ្ជាក់៖</u> ការទូទាត់ដោយបង្វែរតាមធនាគារចូលគណនីរបស់ ន.ទ.ក ប្រតិបត្តិករ និងអ្នកទទួលប្រើប្រាស់សេវាទូរគមនាគមន៍ទាំងអស់ជាអ្នកទូទាត់រាល់ចំណាយសោហ៊ុយធនាគារ (Bank Charge) ។

ទទួលបានសេចក្តីជូនដំណឹងខាងលើ សូមឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោកឧកញ៉ា លោក លោកស្រី ជ្រាបជាព័ត៌មាន។

ថ្ងៃ ពុធ ១១កើត ខែ ស្រាពណ៍ ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ សីហា ឆ្នាំ២០១៨

ប្រធាន

ម៉ុង ចរិយា